ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍

# ស្តីពី

# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# (ប្រចាំខែតុលា ឆ្នាំ២០១៣)

## I- សភាពការណ៍រួម

ក្នុងខែតុលា ឆ្នាំ២០១៣ ស្ថានភាពអាកាសធាតុទទួលរងឥទ្ធិពលពីជ្រលងសម្ពាធទាបខ្សោយ ខ្យល់បក់មកពីទិសឦសាន ផ្ទៃមេឃមានពពកពីតិចទៅមធ្យមនិងមានភ្លៀងធ្លាក់តិចតួចនៅតាមតំបន់មួយចំនួននៃរាជធានី ខេត្ត។ ជារួមមកទល់ពេលនេះដំណើរការការងារបង្កបង្កើនផលគ្រប់មុខដំណាំត្រូវបានបញ្ចប់ជាស្ថាពរហើយ ចំពោះដំណាំស្រូវសម្រេចបាន១០៦,៨០ភាគរយ នៃផែនការដាំដុះ២.៣៩៩.៦៣៧ហិកតា។ ដោយឡែកទឹកទន្លេមេគង្គបានស្រកជាបណ្តើរៗហើយ។

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

### ១.១ ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៣

#### ១.១.១ ដំណាំស្រូវ

-ផ្ទៃដីភ្ជួររាស់សរុបចំនួន៣.២៤៩.១១៥ហិកតា (ក្នុងនោះគោ-ក្របីចំនួន៩៦០.៥១៦ហិកតា ស្មើនឹង២៩,៥៦% និងគ្រឿងយន្តចំនួន២.២៨៨.៥៩៩ហិកតា ស្មើនឹង៧០,៤៤%) លើសឆ្នាំមុន៩០.៧០៥ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ១៩៩.៧៧៧ហិកតា

-ផ្ទៃដីសាបសរុបចំនួន១៥៨.៨៨៦ហិកតា តិចជាងឆ្នាំមុន១៧.០៩៩ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ១៤០.៧៤៤ហិកតា

-ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន២.៥៦២.៧៦៤ហិកតា ស្មើនឹង១០៦,៨០% នៃផែនការ២.៣៩៩.៦៣៧ហិកតា លើសឆ្នាំមុន៥១.០៧០ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ១៧១.៨៩៤ហិកតា

- ស្រូវស្រាលចំនួន ៦៥៩.៤៨៧ហិកតា (ក្នុងនោះស្រូវបង្កើនរដូវចំនួន២២៩.៨៦៩ហិកតា) តិចជាងឆ្នាំមុន ១៨.៩៦៦ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ ៦២.២៤៣ហិកតា
- ស្រូវកណ្តាលចំនួន ១.២៣២.៥៤៦ហិកតា លើសឆ្នាំមុន ៤៧.៩៦០ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ ១០៣.៤៤៦ហិកតា
- ស្រូវធ្ងន់ចំនួន ៥៥៧.១២៦ហិកតា លើសឆ្នាំមុន ២៧.៨៦៥ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ ៣៣.៩២៥ហិកតា
- ស្រូវចម្ការចំនួន ៤៧.៥៤៣ហិកតា តិចជាងឆ្នាំមុន ៣.០៣៥ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំ ៣.២១៥ហិកតា
- ស្រូវឡើងទឹកចំនួន ៦៦.០៦២ហិកតា តិចជាងឆ្នាំមុន ២.៧៥៤ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំ ២៤.៥០៤ហិកតា។



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

-ការងារប្រមូលផលស្រូវរដូវវស្សាសម្រេចបានលើផ្ទៃដីចំនួន២៥៣.៦៤១ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន៩១៥.២២៧តោន និងទិន្នផលជាមធ្យមចំនួន៣,៦០៨តោនក្នុងមួយហិកតា

*-ផ្ទៃដីប៉ះពាល់និងខូចខាតដោយកង្វះទឹក ÷*

- សំណាបសរុបចំនួន ៦៣១ហិកតា ក្នុងនោះខូចខាតចំនួន ២៥០ហិកតា
- សន្ទូង-ពង្រោះសរុបចំនួន ៩.៩៩៧ហិកតា។

*-ផ្ទៃដីប៉ះពាល់និងខូចខាតដោយទឹកជំនន់ ÷*

- សំណាបចំនួន ១២០ហិកតា ក្នុងនោះខូចខាតចំនួន ៨២ហិកតា
- សន្ទូង-ពង្រោះសរុបចំនួន ៣៧៤.៨៤៩ហិកតា ក្នុងនោះខូចខាតចំនួន ១២៥.០១១ហិកតា។

១.១.២ ដំណាំរួមផ្សំ

ផ្ទៃដីសម្រេចបានចំនួន៦៥៣.០៩៧ហិកតា ស្មើនឹង១២៦,២៦ភាគរយ នៃផែនការសរុប៥១៧.២៦០ហិកតា លើសឆ្នាំមុន៣៩.២៤១ហិកតា ក្នុងនោះមាន÷

-ផ្ទៃដីដំាពោតចំនួន១៨៩.៨០០ហិកតា លើសឆ្នាំមុន៤.៩៨៩ហិកតា ក្នុងនោះផ្ទៃដីដំាពោតក្រហមមាន ១៧១.១២៤ហិកតា

-ផ្ទៃដីដំឡូងឈើចំនួន៣៨៧.១០៣ហិកតា លើសឆ្នាំមុន៤៨.២៦១ហិកតា

-ផ្ទៃដីដំឡូងជ្វាចំនួន៤.៤៧១ហិកតា លើសឆ្នាំមុន១០៩ហិកតា

-ផ្ទៃដីបន្លែគ្រប់មុខចំនួន២៧.៦៧៥ហិកតា តិចជាងឆ្នាំមុន១១.៦៩៤ហិកតា

-ផ្ទៃដីសណ្តែកបាយចំនួន៤៤.០៤៨ហិកតា តិចជាងឆ្នាំមុន២.៤២៤ហិកតា ។

១.១.៣ ដំណាំឧស្សាហកម្ម

ផ្ទៃដីសម្រេចបាន ១៤៨.៣៨២ហិកតា ស្មើនឹង៩៦,០៨ភាគរយ នៃផែនការសរុប ១៥៤.៤២៩ហិកតា លើសឆ្នាំមុន ២០.៤៣០ហិកតា ក្នុងនោះមាន÷

-ផ្ទៃដីសណ្តែកដីចំនួន ១៦.៩៦៦ហិកតា លើសឆ្នាំមុន ២.២២៤ហិកតា

-ផ្ទៃដីសណ្តែកសៀងចំនួន ៧៩.៧៣៧ហិកតា លើសឆ្នាំមុន ២១.៤៦៧ហិកតា

-ផ្ទៃដីល្ងចំនួន ៣៣.៧១៨ហិកតា តិចជាងឆ្នាំមុន ៣.១៥៣ហិកតា

-ផ្ទៃដីអំពៅចំនួន ១៧.៦៦២ហិកតា តិចជាងឆ្នាំមុន ១៣១ហិកតា

-ផ្ទៃដីក្រចៅចំនួន ២១៦ហិកតា តិចជាងឆ្នាំមុន ២០ហិកតា

-ផ្ទៃដីថ្នាំជក់ចំនួន ៨៣ហិកតា លើសឆ្នាំមុន ៤៣ហិកតា។

## ២ ផ្នែកព្រៃឈើ

### ២.១ ការងារចំណូលព្រៃឈើ

-ចំណូលពីផលព្រៃឈើចូលថវិកាជាតិសរុបចំនួន៨៦.៨២១.៥០៤.២៨៨រៀល ដែលក្នុងនោះផលទុននៃទ្រព្យសម្បត្តិរដ្ឋចំនួន៣៨.៦៦៧.៧០៣.៧៧១រៀល ចំណូលបានមកពីផលទុនពីការលក់-ជួលទ្រព្យសម្បត្តិនិងសេវាចំនួន៦៦.៨៣៧.៤០០រៀល និងចំណូលបានពីការផាកពិន័យឈើដែលបានមកពីការបង្ក្រាបបទល្មើសចំនួន៨.០៨៦.៩៦៣.១១៧រៀល។

### ២.២ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

-ធ្វើសារពើភណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើនៅក្នុងដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ស៊ី អ ឌី ខេត្តរតនគិរី

-ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ចេញពីព្រៃគុបផ្តល់ផលក្រៅពីព្រៃសម្បទាន÷ ឈើហ៊ុបមូលសរុបចំនួន១១.១៨៩ម៣ កូនឈើចំនួន១៧៥.១៣៣ដើម អុសចំនួន១៥.៥៦៨ស្ទែរ ឫស្សីចំនួន៦១៥តោន និងជ័រទឹកចំនួន ៦០តោន។

## ២.៣ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

-ជំរឿនសត្វស្លាបដែលមាននៅក្នុង៤តំបន់អភិរក្សសំខាន់ៗសរុបចំនួន២២៧ប្រភេទ ស្មើនឹង៣៩.៩០៥ក្បាល

-ជំរឿនសត្វត្រយ៉ងចង្កំកសមានចំនួន១៥២ក្បាល នៅតាមតំបន់ទន្លេមេគង្គលើ

-រៀបចំអាហារដ្ឋានត្មាតប្រចាំនៅតំបន់វាលបឹងទាល់នៃព្រៃការពារព្រះវិហារសរុបចំនួន៣៥ក្បាល

-រកឃើញសម្បុកសត្វត្រដក់តូចចំនួន៦៣នៅតំបន់ព្រៃការពារព្រះវិហារ និងប្រមូលពងក្រពើចំនួន៣៣ពងពីមាត់បឹងនៅជាប់ស្ទឹងអារ៉ែង

-ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាសរុបចាប់ពីដើមឆ្នាំ សត្វចំណូលថ្មីចំនួន៦៨៥ក្បាល សត្វកើតថ្មីចំនួន៥៩ក្បាល សត្វដោះលែងចំនួន៤៥១ក្បាល សត្វស្លាប់ចំនួន១១៧ក្បាល ព្យាបាលសត្វចំនួន២២៧ក្បាល យកសំណាកទៅពិសោធន៍ចំនួន២៧២ក្បាល ផ្ញើឲ្យសន្លប់ចំនួន១៥១ក្បាល ទម្លាក់សត្វល្អិតចំនួន៥២៧ក្បាល វះកាត់សាកសពសត្វចំនួន៤៧ក្បាល ដាក់លេខកូដចំនួន២១ក្បាល ចាក់វ៉ាក់សាំងចំនួន៤៦៩ក្បាល ជួសជុលផ្លូវចំនួន២៦៨.៧៩៣ម២ និងភ្ជួរអនាម័យព្រៃ១៨.៤៤៤ម២ សាងសង់ទ្រុងសត្វនិងអគារផ្សេងៗចំនួន៣.៦៤៧ម២ សាងសង់របងហ៊ុមព័ទ្ធនិងទ្រុងសត្វថ្មីលើដីចំនួន១៣.៤៨៨ម២ សាងសង់សំណង់ផ្សេងៗចំនួន១.១២៣ម២ ដាំកូនឈើចំនួន ១.៤២៩ដើម បណ្តុះផ្កាលម្អ(ផ្កាក្រដាស)ចំនួន៣.២៣៨ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន១០.៦៤៤នាក់

-ក្រុមហ៊ុនចំនួន ០៧ កំពុងចិញ្ចឹមស្វាក្តាមចំនួន៧៥.៨៣៧ក្បាល។

## ២.៤ ការងារដាំដើមឈើ

-ស្រាវជ្រាវពូជឈើដូនថែមនៅចម្ការពូជឈើក្នុងព្រៃធម្មជាតិលើផ្ទៃដីសរុបចំនួន៣៥០ហិកតាស្ថិតនៅស្រុកសណ្តាន់ ខេត្តកំពង់ធំ និងចម្ការពូជឈើទាលទឹក នៅស្ថានីយក្បាលឆាយទំហំ៥ហិកតា និងដាំកូនឈើបានចំនួន៨.៣០០ដើម ដើម្បីអភិវឌ្ឍធនធានសេនេទិចព្រៃឈើ

-នៅស្ថានីយដាំឈើរដ្ឋ ការដ្ឋានរបស់ក្រុមហ៊ុនឯកជន ការដ្ឋានដាំឈើដៃគូជាមួយរដ្ឋបាលព្រៃឈើ ផ្នែកឯកជនខ្នាតតូច/ធំ និងអង្គការក្រៅរដ្ឋាភិបាល និងការរៀបចំពិធីបុណ្យរុក្ខទិវា២០១៣ បានឈូសឆាយដីព្រៃចំនួន១៥០ហិកតា ដាំកូនឈើនិងកូនកៅស៊ូជាចម្ការចំនួន៣.២០០ហិកតា

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន៥៧ក្រុមហ៊ុន បានឈូសឆាយដីព្រៃចំនួន១៥០ហិកតា និងដាំកូនឈើនិងកូនកៅស៊ូចំនួន៣.១១០ហិកតា

-ថ្នាលបណ្តុះកូនឈើរបស់រដ្ឋបាលព្រៃឈើអនុវត្ត÷ កូនឈើសល់ស្តុកក្នុងឆ្នាំ២០១២ចំនួន៧៩៨.០៤២ដើម កូនឈើបណ្តុះក្នុងខែចំនួន៩៧៩.៨៥២ដើម និងចែកចាយកូនឈើក្នុងខែចំនួន៧៧៣.៧៥១ដើម

-ការដាំឈើដៃគូជាមួយក្រុមហ៊ុន Think Biotech(Cambodia) Co., Ltd បានដាំកូនឈើប្រភេទអាកាស្យាហាយប្រីតលើផ្ទៃដីទំហំ៧០ហិកតា

-ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើចំនួន០៥របស់រដ្ឋបាលព្រៃឈើ ដាំកូនគ្រញូងបានចំនួន២០ហិកតា

-ដំណាំកសិរុក្ខកម្ម មានឡូត៍ស្រាវជ្រាវប្រព័ន្ធកសិរុក្ខកម្មទំហំ ៥ហិកតា ដែលមានទីតាំងនៅខេត្តកំពង់ធំ កំពុងដំណើរការដាំដុះបាន០៣ហិកតា។

## ២.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

### ២.៥.១ ការងារពាណិជ្ជកម្មនាំចេញ នាំចូល

-ពិនិត្យឯកសារស្នើសុំពាក់ព័ន្ធនឹងការនាំចេញនាំចូលចំនួន០២ក្រុមហ៊ុន

-ផ្តល់អាជ្ញាប័ណ្ណនាំចេញឈើកែច្នៃគ្រប់ប្រភេទជូនក្រុមហ៊ុនចំនួន០២ ដែលមានបរិមាណឈើចំនួន២.១៦៣ម៣។

### ២.៥.២ ការងារឧស្សាហកម្ម

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន០៣ ស្មើនឹង៤២សន្លឹក ដែលមានបរិមាណឈើចំនួន៤.១៦៥ម៣ និងចំណិតឈើចំនួន១.០០០តោន។

## ២.៦ ការងារនីតិកម្មនិងវិវាទ

-បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃសរុបចំនួន១១៣ករណី

-ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើហ៊ុបមូលចម្រុះប្រភេទចំនួន៣២ម³ ឈើអារចំនួន៨៧ម³ ឈើក្រាក់ត្រញូងចំនួន៣៧ម³និង៣.៩១២គ.ក្រ កូនឈើចំនួន០៩ដើម ឈើជន្លង់ម្រេចចំនួន១៤១ដើម អុសចំនួន៣០ស្ទែរ គល់ឈើ(ធ្នង់)ចំនួន៦២គល់ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន១៣៦គ.ក្រនិង០៦ក្បាល រថយន្តចំនួន៦៣គ្រឿង ម៉ូតូចំនួន១០គ្រឿង ទូក-កាណូតចំនួន០៣គ្រឿង ម៉ាស៊ីនផ្សេងៗចំនួន០២គ្រឿង ម៉ូទ័រចំនួន០៤គ្រឿង រណារយន្តចំនួន០២គ្រឿង និងសម្ភារផ្សេងៗទៀត ព្រមទាំងដកហូតដីព្រៃឈើចំនួន២.៤៥៦ហិកតា

-ចុះស្រង់ស្ថិតិដីព្រៃឈើដែលបានកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដកហូតដីព្រៃដែលបានកាប់រានសរុបចំនួន៥៧ហិកតា ។

# ៣ ផ្នែកជលផល

## ៣.១ អាជីវកម្មនេសាទ

### ៣.១.១ នេសាទទឹកសាប

-ដាយគ្រីក្នុងរដូវនេសាទឆ្នាំ២០១៣-២០១៤ សរុបបានចំនួន១.៥០០តោន ស្មើ១៥% នៃផែនការ ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥០០តោន

-នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៣ *ក្នុងខែចំនួន២៥.០០០តោន* សរុបបានចំនួន២០៥.០០០តោន ស្មើ ៦៨,៣៣% នៃផែនការ៣០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២៥.០០០តោន

-នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៣ *ក្នុងខែចំនួន១៥.០០០តោន* សរុបបានចំនួន៩៥.០០០តោន ស្មើ ៦៣,៣៣% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២៥.០០០តោន ។

### ៣.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៣

*-ក្នុងខែចំនួន៩.០០០តោន* សរុបបានចំនួន៨៣.០០០តោន ស្មើ៩២,២២%នៃផែនការ៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៤.០០០តោន។

## ៣.២ វារីវប្បកម្ម

-ការចិញ្ចឹមត្រីនិងបង្គា *ក្នុងខែចំនួន៦.០០០តោន* សរុបបានចំនួន៧១.០០០តោន ស្មើ៨៨,៧៥%នៃផែនការ ៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១.០០០តោន

-ការចិញ្ចឹមក្រពើ *ក្នុងខែចំនួន១០.០០០ក្បាល* សរុបបានចំនួន២០០.០០០ក្បាល ស្មើ១០០% នៃផែនការ ២០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២៥.០០០ក្បាល

-ការភ្ញាស់កូនត្រីពូជ *ក្នុងខែចំនួន១៥.០០០.០០០កូន* សរុបបានចំនួន១២០.០០០.០០០កូន ស្មើ៨០% នៃផែនការ ១៥០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១៥.០០០.០០០កូន ។

## ៣.៣ ការកែច្នៃផលនេសាទ

-ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១២-២០១៣ *ក្នុងខែចំនួន៥.០០០តោន* សរុបបានចំនួន៥៥.០០០តោន ស្មើ៥៥% នៃផែនការ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២៦.០០០តោន

-ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៣ *ក្នុងខែចំនួន៥០០តោន* សរុបបានចំនួន៦.៥០០តោន ស្មើ១០៨,៣៣% នៃផែនការ៦.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៧០០តោន

-ការផលិតទឹកត្រី *ក្នុងខែចំនួន៣.០០០.០០០លីត្រ* សរុបបានចំនួន៤៨.០០០.០០០លីត្រ ស្មើ៨០% នៃផែនការ ៦០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.០០០.០០០លីត្រ។

### ៣.៤ ការនាំចេញផលនេសាទ

-ផលនេសាទស្រស់ *ក្នុងខែចំនួន១.០០០តោន* សរុបបានចំនួន៩.៥០០តោន ស្មើ៤៧,៥០% នៃផែនការ២០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២.០០០តោន

-ផលនេសាទកែច្នៃ *ក្នុងខែចំនួន៥០០តោន* សរុបបានចំនួន៥.០០០តោន ស្មើ៥០% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៨០០តោន។

### ៣.៥ ការការពារប្រភពធនធានជលផល

-កំណត់ហេតុបទល្មើស សរុបចាប់ពីដើមឆ្នាំចំនួន២.៨៦៧ករណី ដែលកើតមាននៅតំបន់ទឹកសាប២.៧៩២ករណី និងតំបន់សមុទ្រ៧៥ករណី ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៨៧២ករណី គឺតំបន់ទឹកសាប៨៩២ករណីនិងតំបន់សមុទ្រថយចុះ២០ករណី។ ជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

### ៣.៦ ការប្រមូលចំណូល

-ចំណូលពីវិស័យជលផល *ក្នុងខែចំនួន៥០.៥១៥.០០០រៀល* សរុបបានចំនួន២.០១១.០០៦.៣៩១រៀល ស្មើ ៦៨,២៤% នៃផែនការ២.៩៤៧.០០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន១.៩៣៦.១៥៧.៧៥៩រៀល។

## ៤ ផ្នែកផលិតកម្មនិងបសុព្យាបាល

### ៤.១ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

-ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺប៉ូសខ្យល់ និងជំងឺប៉េស្តជ្រូក

-រៀបចំធ្វើឱ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

-អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត

-ផ្នែកពិនិត្យវត្ថុវិភាគសរុបចំនួន ៤៥៨សំណាក

-ផ្នែកសរីរោគសាស្ត្រសរុបចំនួន ០៦ក្បាល ។

### ៤.២ ការអនុវត្តវិធានបសុពេទ្យ

-ទទួលទូរស័ព្ទហៅចូលសរុបចំនួន ០៧ករណី មកពីតាមបណ្តារាជធានី ខេត្ត សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព និងរាយការណ៍ពីបក្សីឈឺ ងាប់

-ចុះធ្វើការរឹបអូសទាំងស្រុងនិងជាចំណែកសាច់សរុបចំនួន៥០គ.ក្រ និងត្រួតពិនិត្យបរិមាណសាច់និងផលិតផលមិនស្អាតចំនួន១០គ.ក្រ

-ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅសត្តឃាតដ្ឋានចំនួន២៨លើក កសិដ្ឋានចិញ្ចឹមមាន់ចំនួន២៥លើក កសិដ្ឋានចិញ្ចឹមទាចំនួន៩លើក ទ្រុងចិញ្ចឹមសត្វចំនួន៦លើក បរិវេណភូមិចំនួន១៨លើក កន្លែងទិញលក់ប្រមូលផ្តុំនិងពិឃាតបក្សីចំនួន៤លើក លើមធ្យោបាយដឹកជញ្ជូនចំនួន២២លើក និងកន្លែងស្តុករបស់ក្រុមហ៊ុនចំនួន៥លើក

-ធ្វើការទប់ស្កាត់ចលនាបក្សីនិងផលិតផលបក្សីដែលនាំចូលពីប្រទេសជិតខាង ដោយបានណែនាំប្រជាពលរដ្ឋនិងអាជីវករឱ្យយល់ដឹងពីផលវិបាកដែលបណ្តាលមកពីជំងឺផ្តាសាយបក្សី ។

### ៤.៣ ការងារឡជីវឧស្ម័ន

-ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន

-ផលិតឡជីវឧស្ម័នសរុបចំនួន ១៣១ឡ ។

## ៥ ផ្នែកកៅស៊ូ

### ៥.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០២-២០១១ (ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ (តោន) |
|---|---|---|---|---|---|
| *I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ* | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៣៦៧,៧០ | ៣៧០,៧១ | ២៧០,២៥ | ២១៤,០០ |
| *សរុប I* | | *៣៦៧,៧០* | *៣៧០,៧១* | *២៧០,២៥* | *២១៤,០០* |
| *II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន* | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ៩.៣៥៦,៨៨ | ៦.៦៨៩,៤៤ | ១២.៩៩៥,២២ | ១១.០៦៩,៤៤ |
| ២ | ក្រុមហ៊ុន ស៊ីហ្វក៉ប់ប៊ើលីមីធីត (រតនគីរី) | ៨៦៧,៩៤ | ១.៦២៥,៩០ | ៧៧០,៣៦ | ៥៤០,០០ |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៦៦,៨០ | ៨៨៥,០១ | ៧៩៥,២៨ | ៦១៥,២០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.០៥៦,៣២ | ៣.២៦៦,៩២ | ២.៨២០,២០ | ២.៧៧១,០០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៩៥,៥៨ | ៥.២៥៩,០៨ | ៣.០១៧,៥២ | ២.៤៤១,៦០ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វវិសសស់ (ស្នួល) | ១.៥៦១,៨០ | ២.៨២៤,៤១ | ១.៩២៣,៥៦ | ១.៨២៤,៥០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.២៤៣,២៦ | ១.១៥៩,០០ | ២.៣៣១,១១ | ២.៥២៣,០០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ២.១៣៥,២៩ | ៣.៦៨៧,៥៣ | ៩៨០,៦៣ | ៧៩៩,០០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | | ១.៥៧០,៦៣ | | |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ២.៨៥២,៧២ | ២.៦១៨,៧៥ | ១.៤៧៨,១៨ | ៧៤៤,០០ |
| *សរុប II* | | *២៥.៦៣៦,៥៩* | *២៩.៥៨៦,៦៧* | *២៧.១១២,០៦* | *២៣.៣២៧,៧៤* |
| *III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច* | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | ១៣៥.៨៤៦,០០ | | |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៥២.៥០៥,០០ | ៨២.០៥៦,០០ | ៤០.៣៥៣,២៥ | ៣៩.៥០០,៥០ |
| *សរុប III* | | *៥២.៥០៥,០០* | *២១៧.៥០២,០០* | *៤០.៣៥៣,២៥* | *៣៩.៥០០,៥០* |
| សរុប I+II+III | | ៧៨.៥០៩,២៩ | ២៤៧.៤២៩,៣៨ | ៦៧.៧៣៥,៥៦ | ៦៣.០៤២,២៤ |

### ៥.២ ការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

-បេសកកម្មចុះទៅខេត្តព្រះវិហារ ដើម្បីប្រមូលសំណាកសន្លឹកកៅស៊ូសម្រាប់វិភាគ DNA។

### ៥.៣ ការស្រាវជ្រាវអំពីការបង្កាត់ពូជ

-ចុះស្រង់ទិន្នន័យជំងឺស្លួតមុខចៀរក្នុងឡូត៍ពិសោធន៍កូន IRAA05-IRAA08 នៅចម្ការកៅស៊ូក្រែក

-រៀបចំបើកមុខចៀរឡូត៍ពិសោធន៍កូន IRAA08។

### ៥.៤ ការស្រាវជ្រាវអំពីសរីរវិទ្យានិងអាជីវកម្ម

-ចំពោះប្រព័ន្ធចៀរជ័រពូជ $S/_2$ d3 7d/7 : PB300 ទទួលទិន្នផលខ្ពស់ជាងពូជ GT1 ពូជIRCA230 ពូជPB217 ពូជIRCA109 និងពូជRRIM600 នៅថ្នាំ T2: ET 2.5% Pal (1) $4/_y$ ។

### ៥.៥ ការស្រាវជ្រាវ ការដាំដុះ និងការពារ

-ចូលរួមជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Nagoya ដើម្បីបំពាក់ឧបករណ៍បន្ថែមស្រាវជ្រាវលើដំណាំកៅស៊ូនិងជួសជុល ថែទាំឧបករណ៍ Sap Flow ។

### ៥.៦ ការងារនៅស្ថានីយអនុវត្ត

-លាបថ្នាំរំញោចនិងលាបខ្លាញ់គោ

-ដាក់ជីលើកទី២បានមួយភាគ ស្រោចទឹក និងធ្វើស្មៅជាប្រចាំ

-ប្រមូលផលជ័រស្ងួតបានចំនួន២៩,៣៣តោន។

### ៥.៧ ការងារក្នុងមន្ទីរពិសោធន៍យថាប្រភេទ

-ធ្វើតេស្តវិភាគសំណាកយថាប្រភេទចំនួន៩ភាគសំណាក ដើម្បីបញ្ជាក់គុណភាពការកែច្នៃរបស់រោងចក្រ

-អនុវត្តការងារបច្ចេកទេសតាមប្រព័ន្ធគម្រោង ISO 17025:2005 នៃមន្ទីរពិសោធន៍ដូចជា:

+ រៀបចំគោលដៅនិងគោលបំណងតាមកម្មវិធីប្រព័ន្ធគ្រប់គ្រងគុណភាពសម្រាប់ឆ្នាំ២០១៤

+ សរុបរបាយការណ៍នៃការអនុវត្ត (QMS) និងទិសដៅសម្រាប់ឆ្នាំ២០១៤

+ ធ្វើពន្យារសកម្មឧបករណ៍ពិសោធន៍តាមដាន។

## ៦ ផ្នែករដ្ឋបាល

-ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា *ក្នុងខែចំនួន៣៦៣ច្បាប់* សរុបចំនួន៤.៤១៨ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ *ក្នុងខែចំនួន៣០៦ច្បាប់* សរុបចំនួន៣.៤៣២ច្បាប់ និងទទួលពីរាជធានី ខេត្ត *ក្នុងខែចំនួន១៥៣ច្បាប់* សរុបចំនួន៩៧០ច្បាប់

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត *ក្នុងខែចំនួន៤៦៧ច្បាប់* សរុបចំនួន៧.០២២ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ *ក្នុងខែចំនួន៤៦ច្បាប់* សរុបចំនួន៤៣៧ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ *ក្នុងខែចំនួន២០ច្បាប់* សរុបចំនួន៦៧៥ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៧ ផ្នែកនីតិកម្មកសិកម្ម

### ៧.១ ការងារអាជីវកម្មសម្ភារកសិកម្ម

-ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្មបានចំនួន០១ក្រុមហ៊ុន

-ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មនិងកម្រៃសេវាសាធារណៈបានចំនួន០៦ក្រុមហ៊ុន សម្ភារកសិកម្មចំនួន៥០មុខ សេវាវិភាគជីកសិកម្មចំនួន០៤ក្រុមហ៊ុន ស្មើនឹងចំនួន១៨សំណាក សេវានាំចូលសម្ភារកសិកម្មចំនួន០៤ក្រុមហ៊ុន និងបានប្រមូលកម្រៃសេវាសាធារណៈសរុប ១.៣០០.០០០រៀល

-ផ្តល់លិខិតអនុញ្ញាតនាំចេញ នាំចូលសម្ភារកសិកម្មចំនួន០៤ក្រុមហ៊ុន ក្នុងនោះជីកសិកម្មចំនួន១៨មុខ ស្មើនឹង ៥៧.៣៨០តោននិង៣២០.០០១លីត្រ។

### ៧.២ ការងារមន្ទីរពិសោធន៍

-ទទួលវិភាគលើសំណាកជីកសិកម្មបានចំនួន០៤ក្រុមហ៊ុន សរុបចំនួន១៦សំណាក

-ចុះបញ្ជិកាថ្នាំកសិកម្មចំនួន០៤ក្រុមហ៊ុន ស្មើនឹងចំនួន៧៩មុខ ជីកសិកម្មចំនួន០៧ក្រុមហ៊ុន ស្មើនឹង៣៥មុខ និងចំណីសត្វចំនួន០២ក្រុមហ៊ុន ស្មើនឹង២៩មុខ

-ចុះបញ្ជីឃ្លាំងសន្និធិ(ថ្នាំកសិកម្មនិងជីកសិកម្ម)ចំនួន០៥ក្រុមហ៊ុន និងចែកចាយថ្នាំកសិកម្មនិងជីកសិកម្មចំនួន០៥ក្រុមហ៊ុន។

### ៧.៣ ការងារផ្សព្វផ្សាយ

-ធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីបទដ្ឋានគតិយុត្ត នីតិវិធី និងបទដ្ឋានបច្ចេកទេសក្នុងការគ្រប់គ្រងសម្ភារកសិកម្ម (P3P4) ចំនួន០៤លើក នៅខេត្តកំពង់ធំ កំពង់ចាម ស្វាយរៀង និងខេត្តព្រៃវែង។

## ៧.៤ ការងារវិវាទកសិកម្មនិងស្រាវជ្រាវ

-ចុះត្រួតពិនិត្យការនាំចូលសម្ភារកសិកម្មចំនួន០១ក្រុមហ៊ុន

-ចុះត្រួតពិនិត្យមូលដ្ឋានអាជីវកម្មសម្ភារកសិកម្មចំនួន០៣ខេត្ត សរុបចំនួន២៣ករណី និងចាត់វិធានការច្បាប់ចំនួន៣២ករណី។

## ៨ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-ចូលរួមកិច្ចប្រជុំអ្នកសម្របសម្រួលថ្នាក់ជាតិក្នុងបណ្តាប្រទេសអាស៊ាន ស្តីពីការធ្វើឲ្យប្រសើរឡើងពីការយល់ដឹងនិងការអនុវត្តនៃសន្ធិសញ្ញាអន្តរជាតិអំពីធនាគារពន្ធុនៃរុក្ខជាតិសម្រាប់ស្បៀងនិងកសិកម្ម ដែលប្រព្រឹត្តទៅនៅប្រទេសជប៉ុន

-ចូលរួមកិច្ចប្រជុំត្រៀមរៀបចំវគ្គបណ្តុះបណ្តាលស្តីអំពីការអភិវឌ្ឍន៍បច្ចេកទេសកសិកម្មនិងប្រព័ន្ធផ្សព្វផ្សាយកសិកម្មដែលជាគម្រោងស្ថិតនៅក្រោមកិច្ចសហប្រតិបត្តិការកសិកម្មកម្ពុជា-កូរ៉េ

-បន្តការងារពិសោធន៍ស្រាវជ្រាវនៅក្នុងវិទ្យាស្ថាននិងតាមរាជធានី ខេត្តក្នុងព្រះរាជាណាចក្រកម្ពុជា

-ចុះត្រួតពិនិត្យនិងប្រមូលសំណាកដីដើម្បីវិភាគគីមីនៅខេត្តបាត់ដំបង

-ចុះត្រួតពិនិត្យការងារពិសោធន៍និងជួបប្រជុំកសិករនៅខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ

-ចុះប្រមូលព័ត៌មានអំពីជីវភាពរស់នៅរបស់ប្រជាជនដែលពាក់ព័ន្ធនឹងការប្រកបរបរនេសាទត្រីនៅខេត្តកណ្តាល។

## ៩ សាលាជាតិកសិកម្មព្រែកលៀប

### ៩.១ និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបមានចំនួន១.៥៧២នាក់(ស្រី៥១៣នាក់)ក្នុងនោះ÷

• និស្សិតអាហារូបករណ៍ចំនួន១.២០៥នាក់ ក្នុងនោះស្រី៤៣៨នាក់ ÷

-ថ្នាក់បរិញ្ញា *៩៦២*នាក់ (ស្រី ៣៤៧នាក់ ) សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី

-ថ្នាក់បរិញ្ញារង *២៤៣*នាក់ (ស្រី ៩១នាក់) សិក្សាលើមុខជំនាញក្សេត្រសាស្ត្រ រុក្ខកម្ម ផលិតកម្មនិងបសុព្យាបាល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម ជលផល កសិឧស្សាហកម្ម និងសុរិយោដី។

• និស្សិតបង់ថ្លៃចំនួន១៩៦នាក់ ក្នុងនោះស្រី២៧នាក់ ÷

-ថ្នាក់បរិញ្ញា *១៥៤*នាក់ (ស្រី ២៤នាក់ ) សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី

-ថ្នាក់បរិញ្ញារង *៤២*នាក់ (ស្រី ០៣នាក់) សិក្សាលើមុខជំនាញក្សេត្រសាស្ត្រ រុក្ខកម្ម ផលិតកម្មនិងបសុព្យាបាល និងផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ។

• និស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យចំនួន១៧១នាក់ ក្នុងនោះ ស្រី៤៨នាក់ ÷

-ថ្នាក់បរិញ្ញា *១៣៩*នាក់ (ស្រី ៤២នាក់) សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ និងសុរិយោដី

-ថ្នាក់បរិញ្ញារង *៣២*នាក់ (ស្រី ០៦នាក់) សិក្សាលើមុខជំនាញផលិតកម្មនិងបសុព្យាបាល ។

### ៩.២ ការងារផលិតកម្មនិងស្រាវជ្រាវ

-កសិដ្ឋានដំណាំលម្អបានដាំផ្កា ឈើពណ៌ ដូងតាំង និងពង្រីកពូជបន្ថែមសម្រាប់ការអនុវត្តនិងដាំលម្អក្នុងបរិវេណសាលាជាតិ បណ្តុះកូនក្ងាន ស្លាកន្ទុយកំប្រុក។

១០ សាលាជាតិកសិកម្មកំពង់ចាម

១០.១ និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១២-២០១៣ សរុបមានចំនួន១.៥៥៩នាក់(ស្រី ៦០៨នាក់)ក្នុងនោះ ÷

-និស្សិតអាហារូបករណ៍សរុប១.២៩៥នាក់(ស្រី៥៣៥នាក់)ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់(ស្រី ៣៣៩នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម៣៨២នាក់(ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន ១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ ។

១០.២ ការងារពិសោធន៍ស្រាវជ្រាវ

-ធ្វើការពិសោធន៍ដំណាំសណ្តែកសៀង

-ធ្វើការពិសោធន៍លើប្រសិទ្ធភាពជីអាសូត ផូស្វ័រ ប៉ូតាស្យូម លើការលូតលាស់ដំណាំម្ទេសដៃនាង

-ពិសោធន៍តាមដានការលូតលាស់ជ្រូកមេក្នុងការចិញ្ចឹមតាមរយៈការប្រើប្រាស់ចំណីឧស្សាហកម្ម។

១០.៣ ការងារស្រាវជ្រាវ ផ្សព្វផ្សាយ និងការផ្ទេរបច្ចេកទិជ្ជាកសិកម្ម

-លើកគម្រោងចំនួន១១ស្នើសុំថវិកាសម្រាប់ធ្វើការស្រាវជ្រាវលើប្រធានបទស្តីពីការពិសោធន៍កសិកម្ម វារីវប្បកម្ម បសុវប្បកម្ម និងសង្គមជនបទ

-បន្តការងារស្រាវជ្រាវផលិតកម្មដំណាំស្រូវ ដែលបានឧបត្ថម្ភជំនួយពី ACIAR-CARF

-បន្តការងារស្រាវជ្រាវលើបសុវប្បកម្ម ដែលបានឧបត្ថម្ភជំនួយពី DEL-phe(UK)

-ផ្សព្វផ្សាយពីការធ្វើឥណទានស្រូវពូជ ជ្រូកពូជ និងចាក់វ៉ាក់សាំងការពារជំងឺសត្វគោ-ក្របី នៅតាមមូលដ្ឋានឃុំ-ស្រុក ក្នុងខេត្តកំពង់ចាម

-ផ្តល់ជ្រូកពូជជូនដល់កសិករក្រីក្រនៅស្រុកត្រាំកក់ខេត្តតាកែវនិងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមបានចំនួន១៨គ្រួសារ

-ធ្វើការប្រជុំកសិករណែនាំពីការប្រើប្រាស់ថ្នាំពុលគីមី ជីគីមី និងជីសរីរាង្គ នៅក្នុងមូលដ្ឋានស្រុកត្រាំកក់ ខេត្តតាកែវ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

១២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

-និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៥.៦៥៧នាក់ (ស្រី១.២៣៣នាក់) ចែកចេញជា០៩មហាវិទ្យាល័យគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រកៅស៊ូ ដែលសិក្សាតាម កម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន២៥លើក និងក្រៅប្រទេសចំនួន២១លើក និងសិក្ខាសាលាក្នុងប្រទេស ចំនួន២៤លើក និងក្រៅប្រទេសចំនួន២២លើក

-បញ្ជូននិស្សិតទៅចូលរួមវគ្គបណ្តុះបណ្តាលនិងកម្មសិក្សានៅក្រៅប្រទេសចំនួន១២នាក់ និងមន្ត្រីរាជការចំនួន ១២នាក់

-បញ្ជូននិស្សិតទៅធ្វើកម្មសិក្សានៅប្រទេសអ៊ីស្រាអែលចំនួន៣០នាក់

-អនុវត្តគម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ចំនួន២៣គម្រោង គម្រោងទាំងនោះមានគម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ ចម្រុះជំនាញផ្នែកវិទ្យាសាស្ត្រកសិកម្ម ផ្នែកវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ ផ្នែកវិទ្យាសាស្ត្រព្រៃឈើ ផ្នែកវិទ្យាសាស្ត្រជលផល

ផ្នែកស្រាវជ្រាវ-ផ្សព្វផ្សាយ ផ្នែករៀបចំដែនដីនិងរដ្ឋបាលដីធ្លី

-ធ្វើការផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមករវាងសាស្ត្រាចារ្យនិងនិស្សិត ព្រមទាំងខិតខំពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិយ៉ាងទូលំទូលាយ ក្នុងទិសដៅពង្រឹងគុណភាពអប់រំឱ្យបានល្អប្រសើរដើម្បីឱ្យមានលក្ខណៈប្រកួតប្រជែង

-បញ្ជូននិស្សិតចុះជួយវាស់វែងដីធ្លីជូនប្រជាជន ដើម្បីចូលរួមអនុវត្តនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លីរបស់រាជរដ្ឋាភិបាលចំនួន៤២៩នាក់ មកពីមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រកសិកម្ម និងសេដ្ឋកិច្ចកសិកម្មនិងជនបទ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួមការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៣នេះត្រូវបានបញ្ចប់ជាស្ថាពរហើយ លើសឆ្នាំមុនបើប្រៀបធៀបរយៈពេលដូចគ្នា។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននឹងកំពុងបន្តចាត់វិធានការជាបន្តបន្ទាប់ដោយសហការជាមួយស្ថាប័ន និងអាជ្ញាធរមូលដ្ឋានដើម្បីចុះតាមដានលើផលដំណាំនិងសត្វពាហនៈជាអាទិ៍÷ បានចាត់ថ្នាក់ដឹកនាំក្រសួងដឹកនាំក្រុមការងារណែនាំពង្រឹងអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ជាប្រចាំ ដើម្បីវាយតម្លៃលើផលប៉ះពាល់និងខូចខាតលើផលដំណាំ និងចាត់វិធានការអន្តរាគមន៍ជាក់ស្តែង ហើយនិងធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការខិតខំថែទាំដំណាំស្រូវនិងយកចិត្តទុកដាក់លើការគ្រប់គ្រងនិងប្រើប្រាស់ទឹកឱ្យមានប្រសិទ្ធភាព ក៏ដូចជាការថែទាំដំណាំផ្សេងៗនិងរក្សាទឹកទុកឱ្យបានគត់មត់នៅចុងរដូវ។

## IV- ទិសដៅ

-ជំរុញតាមដានសភាពការណ៍រាំងស្ងួតនៅចុងរដូវ

-ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១ និង ០២

-បន្តជំរុញកំណត់ព្រំប្រទល់ដែនព្រៃឈើ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីគ្រប់ភាគីពាក់ព័ន្ធ ហើយត្រូវសម្រេចឱ្យបានប្រវែង ១.០០០គីឡូម៉ែត្រ

-ជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

-បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីចំនួន ១០០កន្លែងបន្ថែមទៀត

-បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយពីសារប្រយោជន៍ស្តីពីព្រៃឈើ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេស

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពស្រាវជ្រាវ

-កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

-បន្តចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះដេញថ្លៃផល អនុផលព្រៃឈើដែលរឹបអូសដោយសាលក្រម ដីកាសម្រេច ពិន័យអន្តរការណ៍ និងឈើអញ្ញាតជន(ឈើគ្មានម្ចាស់)នៅទូទាំងប្រទេស

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

-រៀបចំសេចក្តីណែនាំនិងដាក់ឱ្យប្រើប្រាស់សៀវភៅកត់ត្រាឈើចេញចូលតាមរោងសន្និធិផល អនុផលព្រៃឈើ

-បន្តត្រួតពិនិត្យបទល្មើសនេសាទទឹកសាបនៅរាជធានី ខេត្ត ជាពិសេសតំបន់អភិរក្សឱ្យកាន់តែមានប្រសិទ្ធភាព

-បន្តការតាមដានសកម្មភាពអាជីវកម្មនេសាទសមុទ្រ

-បន្តការងារផ្សព្វផ្សាយការអភិវឌ្ឍវិស័យវារីវប្បកម្មនិងការគ្រប់គ្រងធនធានជលផល

-បន្តការងារស្រាវជ្រាវដើម្បីកំណត់អត្តសញ្ញាណកូនត្រីទៅតាមប្រភេទនីមួយៗនៅតាមដងទន្លេមេគង្គ

-រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

-ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី និងជំងឺផ្តាសាយ (A) H1N1

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-ចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍លើកទី ១០៥ ជាមួយ IRA

-អង្កេតទូទៅស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូនិងត្រួតពិនិត្យជំងឺកៅស៊ូ

-ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-ពង្រឹងការងារបញ្ជិកាគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី ខេត្ត

-បន្តចុះពិនិត្យផ្ទាល់ដល់ទីវាលរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់

-បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងគោលការណ៍លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំអំពីការងារគ្រប់គ្រងមន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងធនធានមនុស្សឱ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកម្រិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង

-ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឱ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា

-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិក្នុងវិស័យកសិកម្មឱ្យបានទូលំទូលាយជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-បន្តរៀបចំច្បាប់លិខិតបទដ្ឋានគតិយុត្ត និងអត្ថបទក្រោមច្បាប់តាមអនុវិស័យ ដើម្បីដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឱ្យបានសមស្រប។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ៥ ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**